**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០៤៧ ដនស/ប្រ.ក/ន.ក

# ប្រកាស

# ស្តីពី

# កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ



អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានឃើញអនុក្រឹត្យលេខ២២៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះ កំណត់អំពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ក្នុងគោលបំណងដើម្បី៖

- ធានាសុវត្ថិភាព សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ
- បង្ការគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន
- បង្កើនការទទួលខុសត្រូវរបស់ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ អ្នកជួលសំណង់ និងអ្នកប្រើប្រាស់សំណង់ចំពោះគ្រោះថ្នាក់ដែលអាចកើតឡើងជាយថាហេតុពីសំណង់
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសំណង់ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ លើកលែងតែប្រភេទសំណង់ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**ប្រការ៣._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់** សំដៅដល់ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ត្រីត្រួតពិនិត្យសំណង់នៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ត្រីត្រួតពិនិត្យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត សម្រាប់សំណង់ដែល

វិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីត្រួតពិនិត្យសំណង់នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

- **អង្គភាពមានសមត្ថកិច្ច** សំដៅដល់អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- **ឯកសារបញ្ជាក់អំពីការកាន់កាប់ដីស្របច្បាប់** សំដៅដល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ភតិសន្យាអចលនវត្ថុ ឬគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងករណីម្ចាស់សំណង់មិនមែនជាម្ចាស់ដី ត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់ដី។

## ជំពូកទី២
## ការចាត់ថ្នាក់កម្រិតសភាពគ្រោះថ្នាក់

**ប្រការ៤._**

សភាពគ្រោះថ្នាក់របស់សំណង់ មាន២(ពីរ)ប្រភេទរួមមាន ប្រភេទគ្រោះថ្នាក់អាចកើតឡើងភ្លាមៗនិងប្រភេទគ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ។

ការចាត់ថ្នាក់កម្រិតសភាពគ្រោះថ្នាក់របស់សំណង់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៥._**

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ច ទទួលបានបណ្តឹងឬព័ត៌មានអំពីសំណង់ដែលមានសភាពគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ច ត្រូវសម្រេចធ្វើការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់នោះ។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ដើម្បីចុះត្រួតពិនិត្យវាយតម្លៃ និងធ្វើការសន្និដ្ឋានអំពីការចាត់ថ្នាក់កម្រិតសភាពគ្រោះថ្នាក់របស់សំណង់ជាបន្ទាន់។

ក្នុងករណីពិនិត្យឃើញថាគ្រោះថ្នាក់អាចកើតឡើងភ្លាមៗ មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធជាបន្ទាន់ តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន។

**ប្រការ៦._**

របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវដាក់ជូនអាជ្ញាធរមានសមត្ថកិច្ច តាមរយៈប្រធានអង្គភាពមានសមត្ថកិច្ច ក្នុងរយៈពេលគិតចាប់ពីថ្ងៃសម្រេចធ្វើការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់៖

- យ៉ាងយូរ១០(ដប់)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យ៉ាងយូរ៥(ប្រាំ)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- យ៉ាងយូរ៣(បី)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

គំរូទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ។

**ប្រការ៧._**

ក្នុងករណីចាំបាច់ អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវម្ចាស់សំណង់ឱ្យផ្តល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់វិស័យឯកជន ដោយរាល់ការចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

រាល់ការចំណាយលើសេវាត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់វិស័យឯកជនសម្រាប់ចំណែករួមនៃអគារសហកម្មសិទ្ធិឬបុរី ជាបន្ទុករួមគ្នារបស់ម្ចាស់នៃចំណែកឯកជនឬកម្មសិទ្ធិករទាំងអស់ ទៅតាមសមាមាត្រនៃផ្ទៃក្រឡាកម្រាលសំណង់របស់ចំណែកឯកជននីមួយៗ ឬផ្ទៃក្រឡាដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀត។

**ប្រការ៨._**

មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អាចចូលបំពេញការងារនៅក្នុងទីតាំងណាមួយបានលុះត្រាតែមានការយល់ព្រមពីម្ចាស់ទីតាំង។

មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អាចចូលបំពេញការងារនៅក្នុងអគារឬសំណង់ដែលបើកចំហដល់សាធារណជនតែនៅក្នុងម៉ោងធ្វើការនៅទីតាំងនោះ។

មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អាចចូលបំពេញការងារនៅក្នុងទីតាំងអចលនវត្ថុឯកជន នៅក្រោយម៉ោង៦(ប្រាំមួយ)ព្រឹក និងមុនម៉ោង១៨(ដប់ប្រាំបី)ល្ងាច។

ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ នៅក្រៅម៉ោងពេលដូចមានកំណត់ក្នុងប្រការនេះ មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា។

**ប្រការ៩.**_

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

លិខិតបញ្ជាបេសកកម្មសម្រាប់មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវចម្លងជូនម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ជាបន្ទាន់តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន។

## ជំពូកទី៣
## ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់

**ប្រការ១០.**_

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចចេញវិធានការបញ្ចៀសគ្រោះថ្នាក់សម្រាប់សំណង់នីមួយៗ ទៅតាមបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់។

ក្នុងករណីគ្រោះថ្នាក់អាចកើតឡើងភ្លាមៗចំពោះសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានសមត្ថកិច្ចចេញវិធានការបញ្ចៀសគ្រោះថ្នាក់ផ្អែកតាមរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់របស់អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ។

ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ ត្រូវធ្វើឡើងទៅតាមប្រភេទនិងកម្រិតនៃសភាពគ្រោះថ្នាក់របស់សំណង់និងផ្អែកតាមរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

អង្គភាពមានសមត្ថកិច្ច ត្រូវយកលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ទៅបិទផ្សាយជាសាធារណៈនៅទីតាំងសំណង់ដែលមានសភាពគ្រោះថ្នាក់នោះ។

**ប្រការ១១.**_

ក្នុងករណីគ្រោះថ្នាក់អាចកើតឡើងភ្លាមៗ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ អ្នកជួលសំណង់ និង/ឬអ្នកកំពុងស្ថិតនៅក្នុងទីតាំងសំណង់ជាបន្ទាន់ តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបានអំពីវិធានការបញ្ចៀសគ្រោះថ្នាក់។

វិធានការបញ្ចៀសគ្រោះថ្នាក់ដែលអាចកើតឡើងភ្លាមៗ មានជាអាទិ៍៖

- ជម្លៀសមនុស្សចេញពីសំណង់ដែលមានសភាពគ្រោះថ្នាក់
- កំណត់អត្តសញ្ញាណសំណង់ជិតខាងដែលអាចរងផលប៉ះពាល់និងជម្លៀសមនុស្សចេញពីសំណង់ទាំងនោះ
- ហ៊ុមព័ទ្ធ ហាមចូល ហាមប្រើប្រាស់ និងហាមអ្នកគ្មានភារកិច្ចចេញចូល

- រុះរើសំណង់ឬផ្នែកណាមួយនៃសំណង់ដែលអាចបង្កគ្រោះថ្នាក់
- កំណត់បរិវេណសុវត្ថិភាព
- បិទផ្សាយជាសាធារណៈនូវលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់នៅទីតាំងសំណង់។

**ប្រការ១២._**

ក្នុងករណីគ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់អំពីវិធានការបញ្ចៀសគ្រោះថ្នាក់។

វិធានការបញ្ចៀសគ្រោះថ្នាក់ដែលមិនអាចកើតឡើងភ្លាមៗ មានជាអាទិ៍៖

- តម្រូវឱ្យម្ចាស់សំណង់ជួសជុល កែប្រែ ឬរុះរើសំណង់ឬផ្នែកណាមួយនៃសំណង់
- តម្រូវឱ្យម្ចាស់សំណង់រកអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដើម្បីសិក្សារកវិធីសាស្ត្របញ្ចៀសគ្រោះថ្នាក់
- តម្រូវឱ្យម្ចាស់សំណង់ចាត់ចែងអនុវត្តតាមការផ្តល់យោបល់បច្ចេកទេសរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់
- តម្រូវឱ្យម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់ ចាត់វិធានការចាំបាច់នានាដើម្បីធានាសុវត្ថិភាព សុខភាព និងទ្រព្យសម្បត្តិរបស់អតិថិជន អ្នកប្រើប្រាស់សំណង់ និងអ្នកជិតខាង
- បិទផ្សាយលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់នៅទីតាំងសំណង់។

រាល់ការចំណាយដើម្បីអនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ ជាបន្ទុករបស់ម្ចាស់សំណង់។

**ប្រការ១៣._**

លិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ ត្រូវកំណត់រយៈពេលសម្រាប់អនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ដោយម្ចាស់សំណង់ និងរយៈពេលសម្រាប់អនុវត្តសិទ្ធិតវ៉ារបស់ម្ចាស់សំណង់។

អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់រយៈពេលសម្រាប់អនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ដោយម្ចាស់សំណង់ ទៅតាមកម្រិតនៃការប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ និងកម្រិតនៃហានិភ័យដែលសំណង់អាចបង្កដល់មនុស្សនិងទ្រព្យសម្បត្តិរបស់អ្នកជិតខាងនិងសាធារណជន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់រយៈពេលសម្រាប់អនុវត្តសិទ្ធិតវ៉ារបស់ម្ចាស់សំណង់ទៅតាមប្រភេទនិងកម្រិតនៃសភាពគ្រោះថ្នាក់របស់សំណង់ ប៉ុន្តែរយៈពេលនេះមិនត្រូវយូរជាង៖

- ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ១៤._**

ក្នុងករណីម្ចាស់សំណង់មិនយល់ព្រមចំពោះវិធានការបញ្ចៀសគ្រោះថ្នាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ច ម្ចាស់សំណង់មានសិទ្ធិស្នើសុំឱ្យធ្វើការវាយតម្លៃ ឬការចាត់ថ្នាក់កម្រិតនៃសភាពគ្រោះថ្នាក់របស់សំណង់ឡើងវិញ ឬផ្តល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ក្នុងវិស័យឯកជនផ្សេងទៀត។

**ប្រការ១៥._**

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់ មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច និងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ចិរវេលាអតិបរមានិងទណ្ឌកម្មជាយថាហេតុសម្រាប់ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់ ឱ្យអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ ដូចមានកំណត់នៅក្នុងលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់។

**ប្រការ១៦._**

ក្នុងករណីម្ចាស់សំណង់មិនធ្វើការរុះរើសំណង់ដែលមានសភាពគ្រោះថ្នាក់ ដូចមានកំណត់នៅក្នុងសេចក្តីជូនដំណឹងស្តីពីវិធានការបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់ចែងធ្វើការរុះរើសំណង់នោះដោយផ្ទាល់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន ដោយរាល់ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

## ជំពូកទី៤
## នីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

**ប្រការ១៧._**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់របស់ខ្លួន។

**ប្រការ១៨._**

បញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ មានបង្ហាញជាអាទិ៍ ទីតាំងនៃសំណល់ ប្រភេទនៃសំណល់ មុខងារប្រើប្រាស់សំណល់ អត្តសញ្ញាណរបស់ម្ចាស់សំណល់និងអ្នកគ្រប់គ្រងសំណល់ កម្រិតនៃសភាពគ្រោះថ្នាក់ និងវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់ត្រួតពិនិត្យ តាមដាន និងចាត់វិធានការពង្រឹងការអនុវត្តច្បាប់។

អង្គភាពមានសមត្ថកិច្ចមានភារកិច្ចគ្រប់គ្រងនិងធ្វើបច្ចុប្បន្នកម្មបញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ ជាឯកសាររឹង និងឯកសារទម្រង់អេឡិចត្រូនិក។

គំរូទម្រង់បញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ ជាឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ១៩._**

អង្គភាពមានសមត្ថកិច្ចមានភារកិច្ចត្រួតពិនិត្យនិងតាមដានរាល់សំណល់ដែលត្រូវបានចុះក្នុងបញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ និងលើកសំណើជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចេញវិធានការបញ្ចៀសគ្រោះថ្នាក់ ឬដកចេញពីបញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់។

**ប្រការ២០._**

ម្ចាស់សំណល់ អ្នកគ្រប់គ្រងសំណល់ និង/ឬអ្នកផ្ទុលសំណល់ដែលមានក្នុងបញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីនៃអង្គភាពមានសមត្ថកិច្ច ក្នុងការត្រួតពិនិត្យ តាមដាន និងចាត់វិធានការបញ្ចៀសគ្រោះថ្នាក់ និងត្រូវរាយការណ៍អំពីស្ថានភាពនៃការប្រែប្រួលរបស់សំណល់ជូនអាជ្ញាធរមានសមត្ថកិច្ច។

## ជំពូកទី៥

## បណ្តឹងតវ៉ា

**ប្រការ២១._**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច ដូចមានចែងក្នុងប្រកាសនេះ មានសិទ្ធិតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬទៅតុលាការតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ២២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៣.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៤រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

  **"ដើម្បីជូនជ្រាប"**
- សាលារាជធានី ខេត្ត
- ដូចប្រការ២៣ **"ដើម្បីអនុវត្ត"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃប្រកាសលេខ ០៤៣ ឋនសា/ប្រាកន៍.ក ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២២ ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

*គំរូទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបសញ្ញា

**ឈ្មោះស្ថាប័ន**

ឈ្មោះអង្គភាព

លេខ : ................

**សូមគោរពជូន**

______________________________________________

**កម្មវត្ថុ៖** របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ____________

មានទីតាំងស្ថិតនៅលើដីឡូត៍លេខ ________ ផ្លូវលេខ ______ ក្រុមទី ____ ភូមិ ________

ឃុំ សង្កាត់ ____________ ក្រុង ស្រុក ខណ្ឌ _____________ រាជធានី ខេត្ត ________

**យោង៖**-ប្រកាសលេខ _________ ចុះថ្ងៃទី ____ ខែ _____ ឆ្នាំ២០២២ ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

-យោងចំណារ ______________________________________

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមគោរពរាយការណ៍ជូន _____________ មេត្តាជ្រាបថា នៅថ្ងៃទី ___ ខែ ____ ឆ្នាំ២០ ___ មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដឹកនាំដោយ _________________ បានចុះត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់នៅលើដីឡូត៍លេខ ________ ផ្លូវលេខ ______ ក្រុមទី ____ ភូមិ _________ ឃុំ សង្កាត់ __________ ក្រុង ស្រុក ខណ្ឌ ____________ រាជធានី ខេត្ត _____________ ដែលមាន ______________ (ឯកសារបញ្ជាក់អំពីការកាន់កាប់ដីស្របច្បាប់) លេខ _____________ ចុះថ្ងៃទី _____ខែ____ ឆ្នាំ __ ទទួលបានលទ្ធផលដូចខាងក្រោម៖

**១. ព័ត៌មានទូទៅ**

– **ម្ចាស់សំណង់ឈ្មោះ** _____________ ភេទ ____ សញ្ជាតិ ______ ថ្ងៃខែឆ្នាំកំណើត ________
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ______________________
និងប្រពន្ធ/ប្តីឈ្មោះ ______________ សញ្ជាតិ ________ ថ្ងៃខែឆ្នាំកំណើត ________
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ______________________

មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ______ ផ្លូវ ______ ភូមិ_________ ឃុំ សង្កាត់ ___________
ក្រុង ស្រុក ខណ្ឌ ____________រាជធានី ខេត្ត _____________លេខទូរស័ព្ទ ____________

– **ម្ចាស់ដីឈ្មោះ** ______________________(ក្នុងករណីម្ចាស់ដីមិនមែនជាម្ចាស់សំណង់) ភេទ ____
សញ្ជាតិ __________ ថ្ងៃខែឆ្នាំកំណើត ________________ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/
លិខិតឆ្លងដែនលេខ _______________________ និងប្រពន្ធ/ប្ដីឈ្មោះ ________________
សញ្ជាតិ ________ ថ្ងៃខែឆ្នាំកំណើត _________________កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/
លិខិតឆ្លងដែនលេខ ___________________________ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ______
ផ្លូវ ________ ភូមិ___________ ឃុំ សង្កាត់ ____________ក្រុង ស្រុក ខណ្ឌ ___________
រាជធានី ខេត្ត _____________លេខទូរស័ព្ទ ______________

– **អ្នកគ្រប់គ្រងសំណង់ឈ្មោះ** _________________ ភេទ ____ សញ្ជាតិ ______ ថ្ងៃខែឆ្នាំកំណើត
________កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ/លិខិតឆ្លងដែនលេខ _________________
និងប្រពន្ធ/ប្ដីឈ្មោះ ________________ សញ្ជាតិ ________ ថ្ងៃខែឆ្នាំកំណើត ____________
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ____________________________
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ______ ផ្លូវ ______ ភូមិ_________ ឃុំ សង្កាត់ ___________
ក្រុង ស្រុក ខណ្ឌ ____________រាជធានី ខេត្ត _____________លេខទូរស័ព្ទ ____________

– **អ្នកជួលសំណង់ឈ្មោះ** ___________ ភេទ ____ សញ្ជាតិ _______ ថ្ងៃខែឆ្នាំកំណើត________
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ____________________________
និងប្រពន្ធ/ប្ដីឈ្មោះ ________________ សញ្ជាតិ ________ ថ្ងៃខែឆ្នាំកំណើត ____________
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ____________________________
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ______ ផ្លូវ ______ ភូមិ_________ ឃុំ សង្កាត់ ___________
ក្រុង ស្រុក ខណ្ឌ ____________រាជធានី ខេត្ត _____________លេខទូរស័ព្ទ ____________

– **អំពីកិច្ចសន្យា៖**
- កិច្ចសន្យាជួលសំណង់៖ ☐គ្មាន☐មាន ចុះថ្ងៃទី ________ ខែ _______ ឆ្នាំ២០ ____
- កិច្ចសន្យាម៉ៅការសាងសង់៖ ☐គ្មាន☐មាន ចុះថ្ងៃទី ______ ខែ _____ ឆ្នាំ២០ ___

## ២. និដ្ឋភាពច្បាប់

– លិខិតអនុញ្ញាតសាងសង់ ☐គ្មាន☐មាន លេខ _________ ចុះថ្ងៃទី ___ ខែ ___ ឆ្នាំ២០ ____
– លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ☐គ្មាន☐មាន លេខ ____ ចុះថ្ងៃទី __ ខែ __ ឆ្នាំ២០ ____
– លិខិតបិទការដ្ឋានសំណង់លេខ ________________ ចុះថ្ងៃទី ______ ខែ _______ ឆ្នាំ២០ ____
– ឯកសារបញ្ជាក់អំពីការកាន់កាប់ដីស្របច្បាប់ លេខ __________ចុះថ្ងៃទី ____ ខែ ___ ឆ្នាំ២០ ____
– សលាកបត្រក្បាលដីលេខ ____________________ ចុះថ្ងៃទី ________ ខែ ______ ឆ្នាំ២០ ____
– ទំហំដី ___________________ ម²
– កិច្ចសន្យាម៉ៅការសាងសង់ ____________________________________________
– វិញ្ញាបនបត្រធានារ៉ាប់រង ______________________________________________

– លិខិតអនុញ្ញាតផ្សេងៗ ________________________________

## ៣. និដ្ឋភាពបច្ចេកទេស

### ក. ព័ត៌មានទូទៅ

– ឈ្មោះសំណង់________________________ មុខងារប្រើប្រាស់ ________________
ធ្វើអំពី ______________ ចំនួន ________ ជាន់ កម្ពស់________ ម៉ែត្រ ផ្ទៃក្រឡាកម្រាលសំណង់ សរុប ______________ ម៉ែតក្រឡា

– បញ្ចប់ការងារសាងសង់នៅឆ្នាំ ________________________________

– ទីប្រឹក្សាគម្រោង ☐គ្មាន ☐មាន គោត្តនាមនិងនាម/នាមករណ៍ ________________

– អ្នកសាងសង់ ☐ក្រុមហ៊ុន ☐ក្រុមជាង គោត្តនាមនិងនាម/នាមករណ៍ ________________
☐គ្មានអាជ្ញាបណ្ណ ☐មានអាជ្ញាបណ្ណ លេខ ____________ ចុះថ្ងៃទី ____ ខែ _____ ឆ្នាំ២០ ___

– អ្នកគ្រប់គ្រងការដ្ឋាន ☐គ្មាន ☐មាន ឈ្មោះ ________________________

– អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ផ្នែកស្ថាបត្យកម្ម ☐គ្មាន ☐មាន គោត្តនាមនិងនាម/នាមករណ៍ ________________________________

– អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ផ្នែកគ្រឿងផ្គុំសំណង់ ☐គ្មាន ☐មាន គោត្តនាមនិងនាម/នាមករណ៍ ________________________________

### ខ. ការត្រួតពិនិត្យផ្នែកស្ថាបត្យកម្ម

ខ.១- ប្លង់ស្ថាបត្យកម្ម ☐គ្មាន ☐មាន

- អ្នកសិក្សាគម្រោងប្លង់ ☐គ្មាន ☐មាន គោត្តនាមនិងនាម/នាមករណ៍ ______________
☐គ្មានអាជ្ញាបណ្ណ ☐មានអាជ្ញាបណ្ណ លេខ__________ ចុះថ្ងៃទី ____ ខែ ____ ឆ្នាំ២០ __
- អ្នកត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម ☐គ្មាន ☐មាន គោត្តនាមនិងនាម/នាមករណ៍ ________________________________

ខ.២- ស្ថានភាពដែលពិនិត្យឃើញ

- ________________________________________________
- ________________________________________________

### គ. ការត្រួតពិនិត្យផ្នែកគ្រឿងផ្គុំសំណង់

គ.១- ប្លង់គ្រឿងផ្គុំសំណង់ ☐គ្មាន ☐មាន

- អ្នកសិក្សាគម្រោងប្លង់ ☐គ្មាន ☐មាន គោត្តនាមនិងនាម/នាមករណ៍ ______________
☐គ្មានអាជ្ញាបណ្ណ ☐មានអាជ្ញាបណ្ណ លេខ__________ ចុះថ្ងៃទី ____ ខែ ____ ឆ្នាំ២០ __
- អ្នកត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់ ☐គ្មាន ☐មាន គោត្តនាមនិងនាម/នាមករណ៍ ________________________________

គ.២- ស្ថានភាពដែលពិនិត្យឃើញ

- ____________________
- ____________________

ឃ. ការត្រួតពិនិត្យផ្នែកសុវត្ថិភាពអគ្គិភ័យ

– ប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ☐ គ្មាន ☐ មាន អ្នកវិជ្ជាជីវៈឬក្រុមហ៊ុន ____________________

– ____________________

– ____________________

ង. ការត្រួតពិនិត្យផ្នែកប្រព័ន្ធមេកានិក ប្រព័ន្ធអគ្គិសនី និងប្រព័ន្ធទឹក

– ប្លង់ប្រព័ន្ធមេកានិក ☐ គ្មាន ☐ មាន អ្នកវិជ្ជាជីវៈឬក្រុមហ៊ុន ____________________

– ប្លង់ប្រព័ន្ធអគ្គិសនី ☐ គ្មាន ☐ មាន អ្នកវិជ្ជាជីវៈឬក្រុមហ៊ុន ____________________

– ប្លង់ប្រព័ន្ធទឹក ☐ គ្មាន ☐ មាន អ្នកវិជ្ជាជីវៈឬក្រុមហ៊ុន ____________________

– ____________________

– ____________________

– ____________________

ច. កត្តាដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពនិងសុវត្ថិភាពសំណង់

– ____________________

– ____________________

– ____________________

## ៤. ការធ្វើតេស្តសំណង់

– ____________________

– ____________________

– ____________________

## ៥. ចំណាត់ការរបស់អាជ្ញាធរមានសមត្ថកិច្ចនិងការអនុវត្តរបស់ម្ចាស់សំណង់

ក. ចំណាត់ការរបស់អាជ្ញាធរមានសមត្ថកិច្ច

– ____________________

– ____________________

– ____________________

ខ. ការអនុវត្តរបស់ម្ចាស់សំណង់

– ____________________

– ____________________

– ____________________

៦. ឯកសារដែលម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ បានប្រគល់ជូនមន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

____________________

____________________

____________________

____________________

៧. សេចក្តីសន្និដ្ឋាន

ក-ការវាយតម្លៃ

- ទិដ្ឋភាពច្បាប់ ____________________

____________________

- ទិដ្ឋភាពបច្ចេកទេស ____________________

____________________

ខ-យោបល់របស់ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់

- ម្ចាស់សំណង់ ____________________

____________________

- អ្នកគ្រប់គ្រងសំណង់ ____________________

____________________

- អ្នកជួលសំណង់ ____________________

____________________

គ-ការចូលរួមត្រួតពិនិត្យ ☐ គ្មាន ☐ មាន

- ____________________
- ____________________
- ____________________

ឃ-ប្រភេទនិងកម្រិតនៃសភាពគ្រោះថ្នាក់

- ប្រភេទ ____________________
- កម្រិត ____________________

ង-សំណើចាត់វិធានការ

- ____________________
- ____________________
- ____________________

## ៨. ឯកសារភ្ជាប់

**ក-ទីតាំងសំណង់**

- ប្លង់ទីតាំង (google map)
- ប្លង់ទីតាំងសំណង់ក្នុងដីឡូត៍។

**ខ-រូបថតបង្ហាញសញ្ញាណគ្រោះថ្នាក់**

**គ-អត្តសញ្ញាណរបស់ម្ចាស់ដី ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់**

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើ សូម ____________________ មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម ____________________ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

ថ្ងៃទី ខែ ឆ្នាំ២០

**អ្នកធ្វើរបាយការណ៍**

បានឃើញ និងសូមគោរពជូន

____________________ មេត្តាសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

ថ្ងៃទី ខែ ឆ្នាំ២០

**ប្រធានក្រុមការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់**

បានឃើញ និងសូមគោរពជូន

____________________ មេត្តាសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

ថ្ងៃទី ខែ ឆ្នាំ២០

**អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់ ឬ**

**ប្រធានមន្ទីរ ដ.ន.ស.ស. រាជធានី ខេត្ត ឬ**

**ប្រធានការិយាល័យ ដ.ន.ស.ត. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

ឧបសម្ព័ន្ធ២នៃប្រកាសលេខ ០៤៣ ឧនសា/ប្រក/នីក ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២២ ស្ដីពី
កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណល់ដែលមានសភាពគ្រោះថ្នាក់

*គំរូទម្រង់បញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបសញ្ញា

**ឈ្មោះស្ថាប័ន**

ឈ្មោះអង្គភាព

លេខ : ........

**បញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់**

| ល.រ | លេខយោង | សំណល់ | ទីតាំង | មុខងារប្រើប្រាស់ | ម្ចាស់សំណល់ | អ្នកគ្រប់គ្រងសំណល់ | កម្រិតនៃសភាពគ្រោះថ្នាក់ | វិធានការ |
|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥
ថ្ងៃទី ខែ ឆ្នាំ២០

**អ្នករៀបចំបញ្ជី**

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥
ថ្ងៃទី ខែ ឆ្នាំ២០

**ប្រធានអង្គភាពមានសមត្ថកិច្ច**

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ
https://t.me/oa_channel

**Link**: Scan QR Code

Contact Admin: t.me/oa_admin